# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ៦១ ព្រទ.កព-៩៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
## សូមក្រាបបង្គំទូលថ្វាយ សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១
## និងជម្រាបជូន សម្តេចនាយករដ្ឋមន្ត្រីទី២

សូមទ្រង់ជ្រាប សូមជ្រាប។

**កម្មវត្ថុ:** អំពីការដកហូតសម្ភារៈពីជនល្មើស ។

ទូលព្រះបង្គំខ្ញុំ សូមទូលថ្វាយសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយកមន្ត្រីទី២ ទ្រង់ជ្រាបថា កន្លងមកនៅតាមបណ្តាតុលាការខេត្ត-ក្រុង មានការលំបាកលើការចោទប្រកាន់ចំពោះបទល្មើសអាជ្ញាដោយហេតុថា មានការបាត់បង់វត្ថុតាង ឬវត្ថុសម្ភារៈអំណូសជាបណ្តោះអាសន្នជាច្រើនណាស់ ដែលមានផលវិបាកដល់អង្គការ អយ្យការ និងតុលាការ ក្នុងការអនុវត្តតាមនីតិវិធីដែលមានចែងក្នុងច្បាប់ដូចករណីចម្លងថ្វាយ និងជូនជាប់មកជាមួយនេះ ។ វត្ថុតាងគឺជាសក្ខីភាពសម្រាប់ធ្វើជាមូលដ្ឋានបង្អែកសំខាន់ណាស់ ដែលមន្ត្រីនគរបាលយុត្តិធម៌ក្រោយពីបានដកហូតពីជនល្មើសរួចហើយត្រូវបញ្ជូនក្នុងរយៈពេលដ៏ខ្លីបំផុតទៅព្រះរាជអាជ្ញាអមសាលាជម្រះក្តី ដើម្បីធ្វើការចោទប្រកាន់ទៅតុលាការតាមផ្លូវច្បាប់ ។

ហេតុនេះ ក្នុងករណីដែលអង្គការសាមីទាំងឡាយមិនផ្តល់វត្ថុតាង ឬវត្ថុដកហូតពីជនល្មើស ឬក៏ផ្តល់មិនបានគ្រប់ចំនួនតាមសំណូមពរចាំបាច់របស់តុលាការទេនោះ ចាប់ពីថ្ងៃនេះទៅព្រះរាជអាជ្ញា និងធ្វើការចោទប្រកាន់លើជនប្រព្រឹត្តល្មើសច្បាប់នោះហើយ ។

សេចក្តីដូចបានទូលថ្វាយ និងជម្រាបជូនខាងលើ ទូលព្រះបង្គំខ្ញុំ សូមសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយករដ្ឋមន្ត្រីទី២ មេត្តាជ្រាប និងអនុញ្ញាតឱ្យអនុវត្តគោលការនេះ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៩៦

**រដ្ឋមន្ត្រី**

**ចែម ស្ងួន**

<u>ចម្លងជូន</u>

-ក្រសួងមហាផ្ទៃ
-ក្រសួងការពារជាតិ
-អគ្គសេនាធិការកងរាជអាវុធហត្ថ
-ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ នឹងនេសាទ
-កាលបវត្ត ឯកសារ
-អយ្យការ និងគ្រប់តុលាការខេត្ត ក្រុង